**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៥

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩
ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងភាគីពាក់ព័ន្ធក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ថ្ងៃនេះ ជាថ្មីម្តងទៀត ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកធ្វើជាអធិបតីក្នុងពិធីបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៥ ដ៏មហោឡារិកនេះ បន្ទាប់ពីកិច្ចប្រជុំពេញអង្គដែលបានប្រព្រឹត្តទៅកាលពីព្រឹកម្សិលមិញ។

ក្នុងឱកាសដ៏ប្រពៃនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងសន្និបាត ដែលជាការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២៦ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជារបស់យើង។

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍និងជំងឺអេដស៍ ក្នុងដំណាក់កាលដែលស្ថានភាពជំនួយពីបរទេសមានការធ្លាក់ចុះ។ ម្សិលមិញ យើងបានស្វែងយល់អំពីអាទិភាពសម្រាប់ប្រាំមួយខែបន្ទាប់។ ហើយនៅថ្ងៃនេះ យើងកំណត់ពីរបៀបដែលយើងបង្វែរចំណុចអាទិភាពទាំងនោះឱ្យទៅជាសកម្មភាព។ គោលដៅរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ**

**កម្ពុជា** ក្នុងការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៨ គឺស្ថិតក្នុងលក្ខខណ្ឌនៃការឈានទៅសម្រេចបានរបស់យើង។ ប៉ុន្តែ ម្ចាស់ជំនួយកំពុងកាត់បន្ថយការគាំទ្ររបស់ខ្លួន ដែលយើងត្រូវប្រឈមនឹងស្ថានភាពមួយដែលធនធានមានកំណត់ ពេលវេលាដែលមានខ្លី ហើយនឹងគោលដៅមានមហិច្ឆតាខ្ពស់។

ក្នុងពេលផ្លេរដំណាក់កាលនេះ យើងទាំងអស់គ្នាបានចាប់ផ្តើមបំពេញតួនាទីក្នុងភាពជាម្ចាស់រួមជាមួយនឹងការពង្រឹងភាពជាអ្នកដឹកនាំ ជាពិសេសការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត ព្រមទាំងអង្គការដៃគូ សំដៅពង្រីកសក្តានុពលនៃបទអន្តរាគមន៍នានា ព្រមទាំងធ្វើការសិក្សាស្រាវជ្រាវ និងជំរុញលើកទឹកចិត្តអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ឱ្យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ដើម្បីឈានឆ្ពោះទៅសម្រេចបានគោលដៅ៩៥ទី១។

ចំណុចស្នូលចំនួនបីដែលទាមទារក្នុងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់គឺៈ ១-គំរូប្រតិបត្តិការរបស់យើង ២-ការធានាហិរញ្ញវត្ថុប្រកបដោយចីរភាពដោយការបង្កើនប្រសិទ្ធភាពធនធានដែលមានស្រាប់ និង៣-អភិបាលកិច្ចល្អ។

ការដកថយរបស់ម្ចាស់ជំនួយពីខាងក្រៅមិនមែនជាការថយក្រោយនោះទេ តែគឺជាលទ្ធផលផ្ទាល់នៃភាពជោគជ័យរបស់យើង ហើយនេះជាកត្តាចាំបាច់ក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ។ ការទទួលខុសត្រូវពេញលេញក្នុងការឆ្លើយតបនឹងជំងឺអេដស៍នឹងស្ថិតនៅក្នុងដៃរបស់យើង។ នេះគឺជាពេលវេលាកំណត់សម្រាប់ភាពជាម្ចាស់របស់ប្រទេសយើង។ ដើម្បីទទួលបានជោគជ័យក្នុងបរិបទថ្មីនេះ យើងត្រូវប្រកាន់យកគោលការណ៍ "បីមួយ" ដែលជាប្រព័ន្ធថាមវន្តដែលភាគីពាក់ព័ន្ធទាំងអស់ដំណើរការក្រោមក្របខណ្ឌរួមមួយៈ

- ផែនការយុទ្ធសាស្ត្រតែមួយៈ សកម្មភាពរបស់យើងត្រូវតែតម្រឹមឱ្យបានល្អសមស្របជាមួយយុទ្ធសាស្ត្រជាតិ។
- យន្តការសម្របសម្រួលតែមួយៈ កិច្ចខិតខំប្រឹងប្រែងទាំងអស់របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវតែបញ្ជូនតាមរយៈអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីលុបចេញការត្រួតជាន់ភារកិច្ច និងបង្កើនប្រសិទ្ធភាព។
- ប្រព័ន្ធតាមដាននិងវាយតម្លៃតែមួយៈ យើងត្រូវតែប្រើប្រព័ន្ធជាតិតែមួយដែលអាចទុកចិត្តបានសម្រាប់ការតាមដានវឌ្ឍនភាព និងការប្រើប្រាស់ធនធាន។

ការងាររួមគ្នារបស់យើងគឺផ្តោតទៅលើសកម្មភាពដែលទាក់ទងគ្នា និងបន្ទាន់ចំនួនពីរ ដែលបង្កើតប្រព័ន្ធថ្មីនេះៈ

### ១- ថ្នាក់ជាតិៈ ការបញ្ចប់យុទ្ធសាស្ត្រចីរភាព និងយន្តការហិរញ្ញវត្ថុរយៈពេលវែង

- ការធ្វើសមាហរណកម្មយុទ្ធសាស្ត្រៈ តម្រឹមការឆ្លើយតបនឹងមេរោគអេដស៍របស់យើងជាមួយនឹងផែនការយុទ្ធសាស្ត្រសុខាភិបាលទី៤(HSP4) ឆ្នាំ២០២៥-២០៣៤ដែលធ្វើឱ្យមានការដាក់បញ្ចូល

ការឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងការថែទាំសុខភាពបឋម(PHC) និងការគ្របដណ្តប់សុខភាពជាសកល(UHC)។

- ផែនទីបង្ហាញផ្លូវប្រកបដោយចីរភាព៖ បញ្ចប់ការពិនិត្យឡើងវិញ ដើម្បីដោះស្រាយបញ្ហាហិរញ្ញវត្ថុសំខាន់ៗ និងគម្លាតរចនាសម្ព័ន្ធ ដោយផ្តល់នូវការណែនាំឆ្ពោះទៅមុខច្បាស់លាស់។
- ការធានាហិរញ្ញប្បទានក្នុងស្រុក៖ ប្រើប្រាស់ការសិក្សាការចំណាយដែលគាំទ្រដោយអង្គការ UNAIDS ដើម្បីបញ្ចូលសេវាសហគមន៍សំខាន់ៗទៅក្នុងកញ្ចប់មេរោគអេដស៍ថ្នាក់ជាតិស្នូល ដោយគ្របដណ្តប់ចន្លោះប្រហោងនៃមូលនិធិសកល តាមរយៈការចុះកិច្ចសន្យាសង្គមដល់តួអង្គមិនមែនរដ្ឋ។

## ២- ថ្នាក់ក្រោមជាតិ៖ ធ្វើវិមជ្ឈការផ្តើមពីសកម្មភាពសំខាន់ដំបូងដែលទាមទារភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់យើង ដោយការផ្លាស់ប្តូរការទទួលខុសត្រូវស្នូលទៅកាន់មូលដ្ឋាន

- ការពង្រីកវិមជ្ឈការឱ្យបានឆាប់រហ័ស៖ ការធ្វើប្រតិភូកម្មនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ទៅថ្នាក់ខេត្ត ស្រុក និងឃុំ សង្កាត់ តាមរយៈការបណ្តុះបណ្តាលនិយាមប្រតិបត្តិ នៃវិមជ្ឈការក្នុងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។
- សមាហរណកម្មថវិកាមូលដ្ឋាន៖ ការដាក់បញ្ចូលដោយជោគជ័យនូវការឆ្លើយតបនឹងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់( CDP) ផែនការវិនិយោគឃុំ សង្កាត់( CIP) ដើម្បីធានាការផ្តល់មូលនិធិដោយថវិកាថ្នាក់ក្រោមជាតិ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា

យើងដឹងយ៉ាងច្បាស់អំពីបញ្ហាប្រឈមនៃកង្វះថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅពេលមានភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយសកល សង្គ្រាម និងសម្ពាធសេដ្ឋកិច្ច។ ដូច្នេះហើយ គោលដៅចុងក្រោយរបស់យើងគឺមិនមែនគ្រាន់តែប្រមូលធនធានប៉ុណ្ណោះទេ ប៉ុន្តែបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដែលមានស្រាប់ ដែលមានទំហំតូច ដើម្បីអនុវត្តសកម្មភាពនៃកញ្ចប់អប្បបរមា និងឱ្យស្របតាមបរិបទក្នុងស្រុក។ កិច្ចខិតខំប្រឹងប្រែងរបស់យើងត្រូវតែសម្រេចបាននូវស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែងដែលមានភាពធន់ មានការសម្របសម្រួលល្អ មានការចុះសម្រុងគ្នា មានភាពតម្រឹម និងមានការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព។

ដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ ការកៀរគរមូលនិធិពីប្រភពដែលមានស្រាប់ ដូចជាថវិកាថ្នាក់ក្រោមជាតិ និងការគាំពារសង្គម គឺជាឱកាសដែលអាចធ្វើទៅបាន ទាន់សភាពការណ៍នៃការធ្លាក់ចុះនូវការគាំទ្រយ៉ាងគំហុកពីដៃគូអភិវឌ្ឍ។

ដោយការគាំទ្រពីម្ចាស់ជំនួយខាងក្រៅធ្លាក់ចុះ ថវិកាជាតិនិងអភិបាលកិច្ចក្នុងស្រុក គឺជាមូលដ្ឋានគ្រឹះនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។ អភិបាលកិច្ចល្អគឺជាយុទ្ធសាស្ត្រថវិកាពចម្បងរបស់យើង។ ខ្ញុំសូមស្នើគ្រប់ក្រសួង ស្ថាប័ន និងជាពិសេសប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តនីមួយៗ បង្ហាញពីភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ តាមរយៈការប្រកាន់ខ្ជាប់ និងភាពម៉ឺងម៉ាត់ចំពោះចំណុចខាងក្រោម៖

- តម្លាភាព និងគណនេយ្យភាព
- ប្រសិទ្ធភាព និងអាទិភាព
- ការត្រួតពិនិត្យ និងតាមដាន។

ទន្ទឹមនឹងនេះ ដូចមានចែងក្នុងគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍ និងថវិកាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ អង្គការសង្គមស៊ីវិល និងបណ្ដាញអ្នកផ្ទុកមេរោគអេដស៍ត្រូវតែទទួលបានការគាំទ្រជាតួអង្គសកម្ម ហើយមិនគ្រាន់តែជាអ្នកទទួលផល នៅក្នុងដំណាក់កាលនៃការធ្វើផែនការថវិកា និងការត្រួតពិនិត្យតាមដាននោះទេ។ អ្នកទាំងនោះជាដៃគូដ៏សំខាន់របស់យើងក្នុងកិច្ចខំប្រឹងប្រែងរួមគ្នា ដើម្បីធានាបានថាការគាំទ្រប្រាកដជាទៅដល់អ្នកដែលត្រូវការបំផុតក្នុងកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ខ្ញុំមានជំនឿយ៉ាងមុតមាំថា អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗកើតចេញពីការអនុវត្តជាក់ស្ដែងរបស់សមាជិក សមាជិកា នៃអង្គសន្និបាត ដែលអាចយកទៅប្រើប្រាស់ក្នុងការកែលម្អ និងអនុវត្តកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្តរៀងៗខ្លួន ឱ្យបានកាន់តែល្អប្រសើរថែមទៀត។

ដើម្បីទុកពេលវេលាឱ្យបានច្រើនសម្រាប់ការធ្វើបទបង្ហាញ ការពិភាក្សា និងការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងចំណោមសមាជិក សមាជិកា នៃអង្គសន្និបាត ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកនាពេលនេះ។

ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ សូមមានសុខភាពល្អ កម្លាំងពលំមាំមួន ដើម្បីចូលរួមពិភាក្សាឱ្យបានផុសផុល ទទួលបានលទ្ធផលតាមកម្មវត្ថុដែលបានគ្រោងទុក។

ខ្ញុំសូមប្រកាសបើក "**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៥**" ចាប់ពីពេលនេះតទៅ។

សូមអរគុណ។